ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ......១១៦៦......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពី

## កាលបរិច្ឆេទកំណត់ឲ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធ ប្រចាំខែឧសភា ឆ្នាំ២០១៤

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា សម្រាប់ការដាក់លិខិតប្រកាស ឬបង់ប្រាក់ពន្ធប្រចាំខែឧសភា ឆ្នាំ២០១៤ ដែលត្រូវចំថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** និង ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ដែលជាថ្ងៃឈប់សម្រាកស្របតាមប្រតិទិនឈប់សម្រាកពីការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ នៅព្រះរាជាណាចក្រកម្ពុជា ។ ដូចនេះកាលបរិច្ឆេទកំណត់ដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធ គ្រប់ប្រភេទប្រចាំខែ រួមទាំងអាករលើតម្លៃបន្ថែម នឹងត្រូវអនុញ្ញាតពន្យាពេលរហូតដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ។ សម្រាប់ខែបន្តបន្ទាប់ ត្រូវអនុវត្តជាធម្មតាដូចមានចែងក្នុងលិខិតជូនដំណឹងលេខ ១០៨៧ អពដ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកំណត់នៃកាលបរិច្ឆេទដាក់លិខិតប្រកាស ឬបង់ប្រាក់ពន្ធនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ បាន ទាន់ពេលវេលា ជាក់ជាពុំខាន ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ

នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៨៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៣

## សេចក្តីជូនដំណឹង

## ស្តីពី

## កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដែលត្រូវចំថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ឬថ្ងៃឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ

៣•៨

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីពង្រឹងការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងមានតម្លាភាព ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ កាលបរិច្ឆេទចុងក្រោយកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដូចមានចែងក្នុងច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ ដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ ឬ អាទិត្យ) ឬថ្ងៃឈប់សំរាកស្របតាមប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធនោះត្រូវលើកទៅថ្ងៃបន្ទាប់ដែលជាថ្ងៃធ្វើការ ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកំណត់កាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន ។ ៚

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល